**_Kundal ini Yoga Cambodia_**
**គុនដាលីនីយ៉ូហ្គា កម្ពុជា**

ផ្លូវ ៣០២ ផ្ទះលេខ ៤២E១ សង្កាត់បឹងកេងកង១, ខណ្ឌ ចំការមន, ភ្នំពេញ

លេខទូរសព្ទ័ ០៩២ ៤២៩ ៨៣៥  អ៊ីម៉ែល: info@KundaliniYogaCambodia

# ព្រឹត្តិបត្រពតិមាន

លេខ២

ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៩

គុនដាលីនីយ៉ូហ្គា កម្ពុជា យើងខ្ញុំ មានក្តីសោមនស្សក្នុងការផ្ញើរជូនលោកអ្នកនូវព្រឹត្តិបត្រពតិមានលេខ២ របស់យើងខ្ញុំ។ យើងខ្ញុំ សង្ឃឹមថា នឹងអាចផ្ញើរជូនលោកអ្នកទៀតនូវព្រឹត្តិបត្រពតិមានថ្មីៗ លើកក្រោយៗទៀត។

មានសកម្មភាពថ្មីៗជាច្រើនកើតឡើងនៅផ្ទះគុនដាលីនីយើងខ្ញុំ ក្នុងខែកន្លងទៅនេះ។ កម្មវិធីរបស់យើងខ្ញុំ បាន និង កំពុងបន្តរីកចំរើនជាលំដាប់ ហើយមានសិស្សកាន់តែច្រើនឡើងៗចាប់អារម្មណ៏នឹងថ្នាក់យ៉ូហ្គា នៅផ្ទះគុនដាលីនីយ៉ូហ្គា។ បច្ចុប្បន្ន យើងខ្ញុំមានគ្រូចំនួន៥នាក់ រួមមាន វ៉ាន់ណាក់, សុរិត្ថា, កនិកា, គីមហុង, និង ចចចៀ កំពុងបង្រៀនជាទៀងទាត់នៅផ្ទះគុនដាលីនីយ៉ូហ្គា។  តូនី និង ហានីកាបង្រៀននៅរៀងរាល់ពេលដែល ពួកគាត់ស្នាក់នៅ ទីក្រុងភ្នំពេញ។

សកម្មភាពបន្ថែមផ្សេងទៀតរបស់យើងខ្ញុំរួមមាន យ៉ូហ្គាសំរាប់កុមារ នៅសាលាជីហ្គីវីងទ្រី *(The Giving Tree)* និង ថ្នាក់យ៉ូហ្គា និង សមាធិ សំរាប់គំរោង នៅវត្ត អូរព័ទ្ធ។

នៅខែមិថុនានេះ យើងខ្ញុំមានបន្ថែមថ្នាក់ជាច្រើនទៀត: មីនឌី និង រ៉ាផែល បង្រៀនថ្នាក់ថ្មីមួយ នៅរៀងរាល់ល្ងាចថ្ងៃព្រហស្បតិ៍ (ម៉ោង ៦ល្ងាច), កនិកា និង គីមហុង មានថ្នាក់ថ្មីមួយនៅរៀងរាល់ល្ងាចថ្ងៃអាទិត្យ (ម៉ោង ៥ល្ងាច)។

នៅរៀងរាល់ថ្ងៃសៅរ៏ នឹងមានថ្នាក់ថ្មីមួយបន្ថែមទៀតសំរាប់ ស្ត្រីមានគភ៌ នៅវេលាម៉ោង ១០ ព្រឹក ដែលបង្រៀនដោយ សូរីតា និង ចចចៀ។

យើងខ្ញុំនឹងបញ្ចប់វគ្គសិក្សាសំរាប់ហ្វឹកហ្វឺនគ្រូកំរិត១ នៅក្នុងខែមិថុនា (៦, ៧ មិថុនា)។ យើងខ្ញុំមានគំរោងនឹងបើក វគ្គសិក្សានេះ ជាថ្មីទៀតនៅបំណាច់ឆ្នាំនេះ។ សំរាប់លោកអ្នកដែលមានចំណាប់អារម្មណ៏ ក៏អាចចូលរៀនបានក្នុង ខែមិថុនានេះ រឺ ចុះឈ្មោះ សិក្សាសំរាប់វគ្គក្រោយ។

សំរាប់ប្រជាជនកម្ពុជាដែលចង់ក្លាយជាបង្រៀននៅផ្ទះ រឺ នៅសហគមន៏របស់ខ្លួន យើងខ្ញុំក៏មានផ្តល់នូវវគ្គសិក្សាពិសេស សំរាប់ថ្នាក់ត្រៀមគ្រូបង្រៀន (Pre-teacher trainning)។

នៅខែមិថុនា យើងខ្ញុំនឹងមានថ្នាក់សិក្សាពិសេសមួយចំនួន ដើម្បីរៃអង្គាសប្រាក់ក្នុងការឧបត្ថម្ភ វ៉ាន់ណាក់ និង សុរិត្ថា ដើម្បីអោយពួកគេទៅចូលរួមវគ្គសិក្សាកំរិតខ្ពស់នៅ អូស្ត្រាលី និង អាមេរិកៈ

- ថ្ងៃសុក្រ ទី ៥, ១២, ១៩ និង ២៦: **MIRACLE MANTRA**
- ថ្ងៃអាទិត្រ ទី១៤: **HEALING YOGA**
- ថ្ងៃព្រហស្បតិ៍ ទី១១ : "ថ្នាក់សំរាប់កុមារ" **(KID'S CLASS)**
- ថ្ងៃអាទិត្រ ទី២១ និង ២៨:  **KUNDALINY YOGA AT ITS BEST**
- ថ្ងៃចន្ទ័ ទី៨: "សមាធិសំរាប់ព្រះច័ន្ទពេញវង់" **FULL MOON MEDITATION**

តំម្លៃឧបត្ថម្ភសំរាប់សកម្មភាពទាំងនេះទាបបំផុតគឺ ៣ដុល្លា ចំពោះជនជាតិខ្មែរ និង ៨ដុល្លា ចំពោះជនបរទេស។  សូមមើលប័ណ្ណផ្សព្វផ្សាយ រឺ គេហទំព័ររបស់យើងខ្ញុំ សំរាប់ពតិមានលំអិត។ យើងខ្ញុំសង្ឃឹមថា លោកអ្នកនឹងអាចចូលរួមសកម្មភាពមួយក្នុងចំនោមសកម្មភាពទាំងនះ។

MIRACLE MANTRA គឺជាម៉ាន់ត្រាដ៏មានឥទ្ធិពលមួយ ដែលអាចធ្វើការកែប្រែនូវទំលាប់របស់មនុស្សម្នាក់ៗអោយបានប្រសើរ បើយើងសូត្រវាបានត្រឹមត្រូវ។ មុនពេលសូត្រម៉ាន់ត្រានេះ អ្នកត្រូវកំនត់នូវភាពស្មោះត្រង់ និង ការតាំងចិត្តក្នុងការកែប្រែខ្លួន និង ការអភិវឌ្ឍ រួចបណ្តោយអោយកំលាំងនៃសំលេង ធ្វើការទៅលើការកំណត់ឡើងវិញនូវភាពភ្លឺថែងចាំង និង ការតាំងចិត្តដ៏មុះមុតរបស់អ្នក។

អរគុណសំរាប់ការគាំទ្រជារៀងរហូតមក របស់លោកអ្នកលើគំរោងគុនដាល់លីនី កម្ពុជា។

យើងខ្ញុំរីករាយនឹងទទួលយកនូវសំណូមពរផ្សេងៗរបស់លោកអ្នក ដើម្បីការអភិវឌ្ឍកម្មវិធីនេះ។

## *Kundalini Yoga Cambodia*

### កាលវិភាគប្រចាំថ្ងៃ

| សៅរ៍ | អាទិត្យ | ច័ន្ទ | អង្គារ | ពុធ | ព្រហស្បតិ៍ | សុក្រ |
|---|---|---|---|---|---|---|
| **07.00-08.30**<br>**Sadhana**<br>-កនិកា- | **07.00-08.30**<br>**Sadhana**<br>-សុរិត្តា- | **06.00-07.30**<br>**Sadhana**<br>គឹមហុង/<br>សិលា | **06.00-07.30**<br>**Sadhana**<br>-កនិកា- | | | |
| **09.30-11.00**<br>**'KY class'**<br>-គឹមហុង- | **09:30-11:00**<br>**'KY class'**<br>-វ៉ាន់ណាក់- | **08.30-10.00**<br>**'KY class'**<br>-វ៉ាន់ណាក់- | **08.30-10.00**<br>**'KY class'**<br>-ចចចៀ- | | **8:30-10:00**<br>**'KY class'**<br>-កនិកា- | **8:30-10:00**<br>**'KY class'**<br>-ចចចៀ- |
| **10:00-11:30**<br>*"យ៉ូហ្គាសំរាប់ស្ត្រីមានផ្ទៃពោះ"*<br>សុរិត្តា /<br>ចចចៀ | | | | | | |
| | **17:00-18:30**<br>**'KY class'**<br>-កនិកា-<br>-គឹមហុង- | **18:00-19:30**<br>*"យ៉ូហ្គាសំរាប់ស្ត្រីមានផ្ទៃពោះ"*<br>ចចចៀ/<br>សុរិត្តា | **17.45-19.00**<br>"ការអនុវត្ត សមាធិសំរាប់ការព្យាបាល"<br>-សុរិត្តា- | | **18:00-19:30**<br>**'KY class'**<br>-មីនឌី-<br>-រ៉ាឆែល- | |

*តំលៃធម្មតា:*

៣ ដុល្លា សំរាប់ ជនជាតិកម្ពុជា

៨ ដុល្លា សំរាប់ ជនបរទេស

*កាតសំរាប់ចូលរួម១០ដង:*

២៥ ដុល្លា (ជនជាតិកម្ពុជា)

៦៥ ដុល្លា (ជនបរទេស)

*Sadhana (លំហាត់ពេលព្រឹក)*

ឧត្ថម្ភប្រាក់តាមសធា

*ថ្នាក់ពិសេស:*

* *យ៉ូហ្គា សំរាប់បញ្ហាខ្នង និង ក*
* Energy Healing (ព្យាបាលដោយប្រើ ថាមពល) និង Reiki Healing (ការព្យាបាល ដោយប្រើដៃ)
* ថ្នាក់ឯកជន
* យ៉ូហ្គា, សមាធិ និង ដំបូន្មានលើរបៀបរស់នៅ

**វគ្គហ្វឹកហ្វឺនគ្រូ (វគ្គសិក្សាវិញ្ញាបណ្ណ័បត្រអន្តរជាតិ, កំរិត១)**

វគ្គក្រោយ: 6-7 មិថុនា (សូមពិនិត្យមើលពេលវេលា)




**វគ្គត្រៀមហ្វឹកហ្វឺនគ្រូ (ថ្នាក់ត្រៀម)**

រៀងរាល់ថ្ងៃព្រហស្បតិ៍ (សូមពិនិត្យមើលពេលវេលា)


គុនដាលីនីយ៉ូហ្គា កម្ពុជា: ផ្លូវលេខ ៣០២, ផ្ទះលេខ ៤២E1, ភ្នំពេញ, កម្ពុជា

អ៊ីម៉ែល: info@KundaliniYogaCambodia.org - គេហទំព័រ: www.KundaliniYogaCambodia.org


*ក្នុងករណីដែលលោកអ្នកមិនចង់ទទួលសារនេះទៀត សូមផ្តល់ព័ត៌មានអោយយើងខ្ញុំ*